## ២.៤ ចីរភាពនៃការផ្គត់ផ្គង់សៀវភៅសិក្សាគោល

### វត្ថុបំណង និង យុត្តិកម្ម

វត្ថុបំណងសំខាន់ ២ នៃកម្មវិធីនេះគឺ ១) ធានាការផ្តល់សៀវភៅសិក្សាឱ្យបានគ្រប់គ្រាន់នៅទូទាំងប្រទេស ២) ផ្តល់អោយសាលារៀនអាចជ្រើសរើសសៀវភៅសិក្សាតាមមុខវិជ្ជានីមួយៗ ។

កម្មវិធីនេះរួមចំណែកឈានទៅសម្រេចវត្ថុបំណងគោលនយោបាយ ESSP ស្តីពីការកែលំអគុណភាពអប់រំនៅបឋមសិក្សា និងមធ្យមសិក្សា តាមរយៈធានាការផ្គត់ផ្គង់ដោយចីរភាពនូវសៀវភៅសិក្សាប្រកបដោយគុណភាព ដែលអាចផ្តល់លទ្ធភាពដល់ការអនុវត្តស្តង់ដាអប្បបរមាថ្មីនៅថ្នាក់ទី ៣ ទី ៦ និងទី ៩ ព្រមទាំងកែលំអកម្មវិធីសិក្សាអប់រំមូលដ្ឋានថ្មីឆ្នាំ ២០០៦-២០១០។ កម្មវិធីនេះក៏ជួយគាំទ្រដល់យុទ្ធសាស្ត្រវិមជ្ឈការដ៏ទូលំទូលាយរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

### អាំងឌីកាទ័រ និង ចំណុចដៅចម្បងៗ

- ធានាការអនុម័តប្រព័ន្ធថ្មីនៃការអភិវឌ្ឍសៀវភៅសិក្សាគោល បោះពុម្ព និងចែកផ្សាយផ្អែកលើគោលនយោបាយនៃការផ្គត់ផ្គង់សៀវភៅសិក្សាអោយមានភាពសំបូរបែបថែមទៀត តាមរយៈការប្រកួតប្រជែងទីផ្សារ ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅត្រឹមខែមីនា ឆ្នាំ ២០០៦ ។
- ផលធៀបសិស្ស-សៀវភៅសិក្សា ១:១ សម្រាប់ថ្នាក់ទី ១-៩ អោយសម្រេចបានចំណុចដៅសម្រាប់គ្រប់កំរិតថ្នាក់នីមួយៗ នៅឆ្នាំទី ១ នៃការអនុវត្តកម្មវិធីសិក្សាថ្មី ។
- ផលធៀបសិស្ស-សៀវភៅសិក្សា ២:១ សម្រាប់ថ្នាក់ទី ១០-១២ នៅតំបន់ប្រជុំជន និងសាលារៀនដែលនៅជិត និងផលធៀបសិស្ស-សៀវភៅសិក្សា ១:១ សម្រាប់សាលារៀននៅតំបន់ជនបទ និងខេត្តដាច់ស្រយាល ។

### យុទ្ធសាស្ត្រ និង វិសាលភាព

ដើម្បីធានាចីរភាពនៃការផ្តល់សៀវភៅសិក្សា ក្រសួងអប់រំ យុវជន និង កីឡា ជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវពិនិត្យឡើងវិញ និងកំណត់តួនាទី និងភារកិច្ចរបស់គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ អ្នកបោះពុម្ពផ្សេងទៀត មន្ទីរអប់រំ យុវជន និង កីឡាខេត្ត-ក្រុង ការិយាល័យអប់រំ យុវជន និង កីឡា ស្រុក-ខ័ណ្ឌ និងសាលារៀនអោយបានច្បាស់លាស់ នៅក្នុងការផ្តល់សៀវភៅសិក្សា ការផលិត និងទិញសៀវភៅសិក្សា ។ ជាងនេះទៀត ក្រសួងអប់រំ យុវជន និង កីឡា នឹងពិនិត្យឡើងវិញពីតួនាទីរបស់នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ នៅពេលខាងមុខ ដោយផ្តោតលើការប្រែក្លាយពីតួនាទីអភិវឌ្ឍសៀវភៅសិក្សា ទៅជាតួនាទីអ្នកពិនិត្យតាមដាន និងវាយតម្លៃសម្ភារឧបទេស និងសៀវភៅសិក្សា ។

**កម្មវិធី និង សកម្មភាពចម្បងៗ**

- ធានាការអនុម័តគោលនយោបាយសៀវភៅសិក្សាថ្មី និងការប្តេជ្ញាចិត្តរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការផ្តល់ហិរញ្ញប្បទានអោយបានទាន់ពេលវេលា ។
- អនុវត្តគោលនយោបាយសៀវភៅសិក្សាថ្មី នៅគ្រប់សាលាបឋមសិក្សា និងមធ្យមសិក្សា ។
- បញ្ចប់ផ្សព្វផ្សាយ និង អនុវត្តស្តង់ដាសិក្សាអប្បបរមា និងកម្មវិធីសិក្សាថ្មីសម្រាប់ការអប់រំចំណេះទូទៅ ។
- កំណត់អោយច្បាស់ពីការគ្រប់គ្រងសៀវភៅសិក្សា និងគោលនយោបាយប្រើប្រាស់ ដើម្បីគាំទ្រដល់ការរៀបចំផែនការ ដែលទាក់ទងទៅនឹងអាយុកាលនៃការប្រើប្រាស់សៀវភៅសិក្សា និងការកំណត់តម្លៃឯកតា សម្រាប់ការផ្គត់ផ្គង់សៀវភៅសិក្សា ។
- ពង្រឹងបណ្តាញបណ្ណាល័យទូទាំងប្រទេសតាមរយៈកម្មវិធីវិលនៃការបង្កើត និងពង្រឹងមជ្ឈមណ្ឌលឯកសារបែបវិមជ្ឈការ ។ ការផ្តោតជាបឋមទៅលើការពង្រឹងមជ្ឈមណ្ឌលឯកសារនៅសាលាគរុកោសល្យ និងវាយតម្លៃសក្តានុពលសម្រាប់ពង្រីករហូតដល់សាលាមធ្យមសិក្សា ។

**ការគ្រប់គ្រង និង ការពិនិត្យតាមដានកម្មវិធី**

- ការគ្រប់គ្រងហិរញ្ញវត្ថុនៃកម្មវិធីនេះ នឹងផ្ទេរពីនាយកដ្ឋានបឋមសិក្សា និងមធ្យមសិក្សា ទៅនាយកដ្ឋាន ស្រាវជ្រាវគរុកោសល្យ ចាប់ពីខែមករា ឆ្នាំ ២០០៦ ។
- នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ ត្រូវទទួលខុសត្រូវផងដែរលើការអនុវត្ត និងការពិនិត្យតាមដានគោលនយោបាយសៀវភៅសិក្សា ស្តង់ដាសិក្សាអប្បបរមា បណ្តាញបណ្ណាល័យ និងគោលនយោបាយអភិវឌ្ឍ កម្មវិធីសិក្សាសម្រាប់ឆ្នាំ ២០០៦-២០១០ ។ មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង បន្តទទួលខុសត្រូវលើ សកម្មភាពពិនិត្យតាមដានការរីកចំរើនលើការផ្គត់ផ្គង់ និងបែងចែកសៀវភៅសិក្សាទៅសាលារៀន ។ អគ្គនាយកដ្ឋានអប់រំ នឹងសម្របសម្រួលក្នុងការធ្វើគំរូតាងសវនកម្មផ្នែកបច្ចេកទេស ហើយអគ្គាធិការដ្ឋាននឹងសម្របសម្រួលលើការធ្វើគំរូតាងសវនកម្មផ្នែកហិរញ្ញវត្ថុ ។

## ផែនការហិរញ្ញវត្ថុ

ហិរញ្ញប្បទានសម្រាប់កម្មវិធីនេះ មានការកើនឡើងគួរអោយកត់សំគាល់ អាស្រ័យដោយកំណើនការចូលរៀនបឋមសិក្សាក្នុងពេលថ្មីៗនេះ និងកំណើនដ៏ឆាប់រហ័សដែលបានគ្រោងទុកនៃការចូលរៀននៅមធ្យមសិក្សា ។ និន្នាការទាំង ២ នេះ តម្រូវឱ្យចំណាយបន្ថែមទៅលើសៀវភៅសិស្ស និងសៀវភៅគ្រូ ។

*តារាងទី ៨ : ផែនការហិរញ្ញវត្ថុសម្រាប់ធ្វើឱ្យមាននិរន្តរភាពនៃការផ្គត់ផ្គង់សៀវភៅសិក្សាគោល*

| សកម្មភាព | ចំណាយគិតជាលានរៀល | | | | |
|---|---|---|---|---|---|
| | **2006** | **2007** | **2008** | **2009** | **2010** |
| **១ ការផ្គត់ផ្គង់សៀវភៅសិក្សាសម្រាប់សាលាបឋមសិក្សា** | 18,152 | 17,922 | 18,072 | 10,572 | 10,572 |
| ១.១ ការផ្គត់ផ្គង់សៀវភៅសិក្សា | 17,872 | 17,722 | 17,872 | 10,372 | 10,372 |
| ១.២ ការអភិវឌ្ឍប្រព័ន្ធ | 130 | 50 | 50 | 50 | 50 |
| ១.៣ ការពិនិត្យតាមដាន | 150 | 150 | 150 | 150 | 150 |
| **២ ការផ្គត់ផ្គង់សៀវភៅសិក្សាសម្រាប់សាលាមធ្យមសិក្សា** | 15,135 | 15,185 | 15,930 | 9,235 | 9,235 |
| ២.១ ការផ្គត់ផ្គង់សៀវភៅសិក្សា | 14,995 | 15,045 | 15,785 | 9,095 | 9,095 |
| ២.២ ការអភិវឌ្ឍប្រព័ន្ធ | 50 | 50 | 50 | 50 | 50 |
| ២.៣ ការពិនិត្យតាមដាន | 90 | 90 | 95 | 90 | 90 |
| **ធនធានសរុប** | **33,287** | **33,107** | **34,002** | **19,807** | **19,807** |

តម្រូវការការកសាងសមត្ថភាព

- កសាងសមត្ថភាពបុគ្គលិកមួយចំនួននៅថ្នាក់កណ្តាល ដើម្បីអនុវត្តគោលនយោបាយថ្មីស្តីពីការអភិវឌ្ឍសៀវភៅសិក្សា និងចាប់ផ្តើមអនុវត្តស្តង់ដាអប្បបរមា និងកម្មវិធីសិក្សាថ្មីសម្រាប់អប់រំចំណេះទូទៅ
- ពង្រឹងសមត្ថភាពពិនិត្យតាមដាននៅថ្នាក់កណ្តាល និងថ្នាក់ខេត្ត-ក្រុង ដើម្បីធានាថាការផ្តល់សៀវភៅសិក្សាទៅអោយស្រុក-ខ័ណ្ឌ និងសាលារៀន បានទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព ។
- ពង្រឹងសមត្ថភាពគ្រប់គ្រង និងបច្ចេកទេសបណ្ណារក្សនៅមជ្ឈមណ្ឌលឯកសារ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យ និង វិក្រឹតការខេត្ត-ក្រុង ។